# សិលាចារឹកស្នាយពល K.៦៦

## ១- ព័ត៌មានទូទៅ

សិលាចារឹកមួយផ្ទាំងនេះ រកឃើញដោយលោក អេត្យេន អែម៉ូនីញ៉េរ នៅបរិវេណវត្តមួយ ក្នុងភូមិស្នាយពល ខេត្តព្រៃវែង ដែលលោកដាក់ប្រភពថាមកពី ភូមិមេលប់ ឬ មេបុណ្យ។[១] ក្នុងសៀវភៅ «ប្រទេសកម្ពុជា» ក្បាលទី១ បោះពុម្ពផ្សាយនៅឆ្នាំ១៩០០ លោកបានបង្ហាញថា មានសិលាចារឹកមួយផ្ទាំង នៅក្នុងវត្តនៅភូមិស្នាយពល ដែលមានទីតាំងប្រមាណជា ៣ ឬ ៤ គីឡូម៉ែត្រ ខាងជើងភូមិកំពង់ពារាំង។[២] ឯលោក ហង់រី ប៉ាម៉ង់ត្យេរ (១៩៣៥) ថាបានឃើញសិលាចារឹកនេះនៅទួលប្រាសាទដែលមានចម្ងាយ ៤៥០ ម៉ែត្រ ស្ថិតនៅជ្រុងឦសានវត្ត។[៣] នៅក្នុងគេហទំព័រ https://cisark.mcfa.gov.kh បញ្ជាក់ថាទីតាំងវត្តស្នាយពល ជាទីតាំងរកឃើញសិលាចារឹកនេះ ស្ថិតនៅចម្ងាយប្រមាណជា ៣ គីឡូម៉ែត្រ ខាងជើងភូមិកំពង់ពារាំង, ប្រមាណជា១,៣ គីឡូម៉ែត្រ ឦសានវត្តពារាំង និង ៤០០ ម៉ែត្រ នៅអាគ្នេយ៍ភូមិស្នាយពល។ នៅក្នុងឆ្នាំ២០០៣ នៅទីនោះមានបំណែករូបចម្លាក់ពីថ្មភក់ និងឈើ។[៤] សិលាចារឹកនេះរក្សាទុកនៅសារមន្ទីរ ល្វី ហ្វីណូត៍ នៅទីក្រុងហាណូយ មុននឹងយកមកសារមន្ទីរភ្នំពេញ នៅក្នុងឆ្នាំ១៩៥៥ បន្ទាប់មកយកទៅរក្សាទុកនៅអភិរក្សអង្គរ ក្នុងឆ្នាំ១៩៦៩។ នៅឆ្នាំ១៩៩៣ បានយកទៅរក្សាទុកនៅក្នុងព្រះបរមរាជវាំង ហើយបានយកមករក្សាទុកនៅសារមន្ទីរជាតិភ្នំពេញវិញ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០២ និងបន្តរក្សាទុករហូតមកដល់សព្វថ្ងៃ។

អត្ថបទចារឹកចារនៅលើថ្មស្រទាប់ រាងទ្រវែង បាក់ជាពីរ ដែលផ្នែកខាងលើមានប្រវែង ៧២ ស.ម. បន្ទារ ២៤ ស.ម. និងកម្រាស់ ៥,៥ ស.ម. ចំណែកផ្នែកខាងក្រោមមានប្រវែង ៦៣ ស.ម. បន្ទារ ២២,៥ ស.ម. និងកម្រាស់ ៤ ស.ម.។ អត្ថបទនេះចារនៅលើផ្ទៃ

[១] Coedès 1942

[២] Aymonier 1900

[៣] Parmentier 1935

[៤] សូមមើលបន្ថែម https://cisark.mcfa.gov.kh/core/showsite.php?id=1419

អត្ថបទដោយៈ ហ៊ុន ឈុនតេង

សង់ខាងនៃថ្ម ដែលផ្ទាំងក មានអត្ថបទចំនួន៣០បន្ទាត់ ប៉ុន្តែត្រង់បន្ទាត់ទី៤ និងទី៥ បានបាត់បង់ ដោយការលុបចេញ ដែលទំនងជាចារខុស និងនៅចន្លោះបន្ទាត់ទី១២ និងទី១៣ មានចារបន្ថែម ដែលយើងហៅថាបន្ទាត់ទី១២ស្ទួន។ ឯផ្ទាំងខ មានចំនួន១៩បន្ទាត់។ នៅលើផ្ទៃផ្ទាំងក នៅខាងលើអត្ថបទនោះ មានឆ្លាក់រូបសង្ខ ដែលលោក អេត្យេន អៃម៉ូនីញ៉េរ (១៩០០) យល់ថាសញ្ញានៅលើផ្ទាំងក គឺជាសញ្ញា «ឱំ» ទៅវិញ។[៥] នៅផ្ទាំងខ មានឆ្លាក់រូបចក្រ ប៉ុន្តែលោក ល្វី ហ្វីណូត៍ (១៩១៥) លោក សេដែស និងអ្នកឯទៀត យល់ថារូបនៅលើផ្ទាំងខនោះ ជារូបព្រះអាទិត្យទៅវិញ ដោយសំអាងថានៅលើអត្ថបទផ្ទាំងនោះ មានឈ្មោះ **ម្រតាញអាទិត្យស្វាមី** ជាអ្នកធ្វើតង្វាយ។[៦] ប៉ុន្តែតាមការសង្កេត រូបនោះពុំសមជារូបព្រះអាទិត្យនោះឡើយ គួរតែជាចក្រទៅវិញទេ គឺចក្ររបស់ព្រះនារាយណ៍។ យើងអាចពិនិត្យទៅលើរូបសញ្ញានៅលើផ្ទាំងសិលាចារឹក K. ១២១៦ នៅលើនោះមានរូបសញ្ញាចំនួនបួន គឺ វជ្រ សង្ខ ត្រីសូល និងចក្រ។ រូប សង្ខ និង ចក្រ គឺជាសញ្ញាតំណាងឱ្យព្រះនារាយណ៍, វជ្រ តំណាងឱ្យព្រះឥន្ទ្រ និងត្រីសូល តំណាងឱ្យព្រះឥសូរ។ រូបសញ្ញាចក្រ នៅលើផ្ទាំងចារឹកនោះ គឺមានលក្ខណដូចគ្នានឹងរូបចក្រ នៅលើផ្ទាំងចារឹកស្នាយពលនេះ ពោលគឺមានកាំចំនួន៨ និងមុខចក្ររាងត្រីកោណ។ ជាពិសេស នៅផ្ទាំងខនៃសិលាចារឹកស្នាយពលនេះ គឺជាបញ្ជីតង្វាយចំពោះព្រះភគវតីព្រះនារាយណ៍។ ដូច្នេះ សិលាចារឹកនេះ គឺជាសិលាចារឹកដែលឧទ្ទិសដល់ព្រះនារាយណ៍ ដែលរូបសញ្ញានៅលើសិលាចារឹកនេះ គួរតែទាក់ទងនឹងព្រះអង្គតែប៉ុណ្ណោះ ពុំទាក់ទងនឹងអ្នកធ្វើតង្វាយនោះទេ។

ចំពោះអត្ថន័យសិលាចារឹកវិញ នៅផ្ទាំងក គឺជារំលឹកដល់ការប្រតិស្ឋានប្រតិមាព្រះនារាយណ៍ និងតង្វាយអ្នកបម្រើ៥០នាក់ជាង ចំពោះប្រាសាទនោះ។ នៅផ្ទាំងខវិញ បង្ហាញអំពីការប្រតិស្ឋានប្រតិមាព្រះភគវតីនៃព្រះនារាយណ៍ ដែលទំនងជាព្រះនាងលក្ស្មី និងថ្វាយតង្វាយអ្នកបម្រើស្រី ដែលអ្នកបម្រើខ្លះ មានកូនផង។

[៥] Aymonier 1900

[៦] Finot 1915

*អត្ថបទដោយៈ ហ៊ុន ឈុនតេង*

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើប

**ផ្ទាំងក**

១- វ្រះកំម្រតាងអញ

២- គ្រីគាលគ្រាម

៣- ស្វាមិ

៤- [អត្ថបទរលុប]

៥- [អត្ថបទរលុប]

៦- កន្ថែបុយាង្វិនៃ[៧] ១ជេងអញ[៨] ១ម្រ

៧- តាញមិត្រាវលិ១ក្ញោ

៨- ញតាង១ក្ញោញឱង១តេលិសិត

៩- តវ្រះ១កុជីវសេន១កុម្រហញ

១០- តាង១កុរំផប[៩] ១កុប្កាឈេ១កុអ

១១- សរុ១កុរនោបរុ១កុរំភា១

១២- កុយនោចិ១កុហ្វេង១កុហេង[១០] ១កុយ

១២(ស្ទួន)- កុកចេនុវត៌[១១]

១៣- ប៉ោញ១កុគុហិ១កុបន្រាង១កុល

១៤- ---កុ--ល្មាសិ១កុ(ប្រ)-១

១៥- (កុ)សុមិ[១២] ១កុប្យោរ៑១កុយ---១

១៦- កុរាហា១កុច្បោង១កុសោចិ

---

[៧] លោក សេដែស អានជា «បូយាង្វិនៃ»។

[៨] ពាក្យ «អញ» ជួសនៅខាងក្រោម។

[៩] អក្សរ «ង» ជួសនៅខាងក្រោម។

[១០] លោក សេដែស អានជា «លាង»។

[១១] ជាឃ្លាដែលចារបន្ថែម បំពេញឈ្មោះដែលភ្លេចចារ។

[១២] លោក សេដែស អានជា «អមិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

១៧- ក្ដោ១កុទិក៌១កុស្ដៅ១កុធនសិ

១៨- និ១កុមញ៑ជរី១កុយរត៑(១)

១៩- កុលចក៌១កុយទត៌១កុស្រ-

២០- យា១កុអំវៃទេសិ១វាភាក៑(១)

២១- វាកំវនិ១វជេម្ពទាស១វាច

២២- តូបី១វាធនករ១វាទ្វិក៌១វា

២៣- សោបិតក៌១វាសអបិ១វាហ្វត៑

២៤- ជ្មហិ១វាវម្ភនទាស១វាក្និ១វា

២៥- ភានុទាស១វាប្របូ្វនិ១វាកោ[១៣]

២៦- កិលិ១វាវ្ថិ១វារមញ៑១

២៧- វាហញ៑នេ១វាចំទកិវ្រះ១

២៨- វាកម្ទ៌អញ៑ទៃ១វាក្និងិ១

២៩- វាបញ្ចមិ១វាទ្វាទគិ១

**ផ្ទាំង ខ**

១- ម្រតាញ៑អាទិត្យស្វាមិទុកិក

២- គវតិឱយិកនិតៃតកគ

៣- វតិបុយាង៑អញ៑[១៤]១សុល

៤- កិអញ៑១ម្រតាង៑អញ៑១

៥- កុបានិ១កោនិកុកុមាថវិ១វា

៦- (ស្នាលលុបចោល) កុត្ងៅ១កោនិកុកុម

៧- លេង៑[១៥]១កុដោង៑១វាចកេ១

៨- កុព្រៅ១កុនិកុវាក្វបិតិ១

---

[១៣] អានជា «ក្ដោ»។

[១៤] អានជា «បូយាង៑អញ៑»។

[១៥] លោក សេដែស អានជា «មលេង៑»។

៩- កុបំរេង៏១កុឱវ៌្គិ១

១០- ---(កុ)---(កុ)---

១១- កោនិកុ[១៦]វាច្កបិ១វាយ

១២- -នះ១កោនិកុរពោហិណិ១

១៣- កុវង៉ាអញ៊ែឆេទ១កុ

១៤- អនង៏១កុលយេ១កោ

១៥- និកុវាបទិហតិ១វា

១៦- អវ៉ៃនុមតិ១វាត្ប

១៧- ញ៊ែ១វាតឥសិ១វា

១៨- តឱង៏១វាលាក១

១៩- វាត្មេង៏១

## ៣- **អត្ថបទប្រែសម្រួល**

### **ផ្ទាំងក**

(១-៥) ព្រះគម្តែងអញស្រីសាលគ្រាមស្វាមី---។

(៦-៩) (តង្វាយ)អ្នកបម្រើគេទស្រី(របស់)បូយាង៍វិនៃ១ ដេង៏អញ១ ម្រតាញមិត្រាវលិ១ ក្ញោញតាញ១ ក្ញោញឱង៏១ ដែលសិត(ទឹក)ថ្វាយព្រះ[១៧]។

(៩-២០) (អ្នកបម្រើស្រីមាន)កុជីវសេន១ កុម្រហញតាង៏១ កុរំង៉ប១ កុផ្កាឈើ១ កុអសរុ១ កុរនោចរុ១ កុរំភា១ កុយនោច១ កុហ្វេង៏១ កុហេង៏១ កុកចេនុវត៌(១) កុយបោញ១ កុគុហិ១ កុបន្ទ្រាង៏១ កុល ---- កុ--ល្មាស១ កុ(ប្រ)-១ (កុ)សុមិ១ កុប្យោរ១ កុយ---១ កុរាហា១ កុប្លោង៏១ កុសោចក្តោ១ កុទិក១ កុស្តៅ១ កុធនសិនិ១ កុមញ្ជរី១ កុយរត១ កុលចក១ កុយទត១ កុស្រ យា១ កុអំរ៉ៃទេស១។

---

[១៦] នៅលើសិលាចារឹកចារជា «កោនិក» ពោលគឺអ្នកចារភ្លេចស្រៈ«ុ»។

[១៧] ត្រង់នេះ អាចអ្នកទាំងនោះធ្វើពិធីសិតទឹកថ្វាយព្រះ រួចទើបថ្វាយអ្នកបម្រើ ឬអាចសិតជាប្រតិមាលោហៈ រួចរាល់ហើយ ទើបថ្វាយតង្វាយ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង៍

(២០-២) (អ្នកបម្រើប្រុសមាន) វាភាក១ វាកំវែន១ វជេម្ទាស១ វាចតូចី១ វាធនករ១ វាទ្វិក១ វាសោចតក៌១ វាសអប១ វាហ្វតផ្សហិ១ វាវម្តនទាស១ វាក្នែ១ វាភានុទាស១ វាប្រច្ចនិ១ វាកោកិល១ វាវ្រីចិ១ វារមញ១ វាហញនេ១ វាចំទកវ្រះ១ វាកម្មអញទៃ១ វាក្វិង១ វាបញ្ចមិ១ វាទ្វាទសី១។

**ផ្ទាំង២**

(១-៤) ម្រតាញអាទិត្យស្វាមី ស្ថាបនា(ប្រតិមា)ព្រះភគវតី (និង)ថ្វាយនារីអ្នកបម្រើ(ទាំងនេះ)ចំពោះព្រះភគវតី (ថ្វាយដោយ)បុយាងអញ១ សុលកអញ១ ម្រតាងអញ១។

(៥-១៩) (នារីអ្នកបម្រើមាន) កុចាន១ កូនរបស់នាង គឺកុមាថរ៉ៃ១ វា---, កុត្នៅ១ កូនរបស់នាងគឺកុមលេង១ កុដោង១ វាចកេ១, កុប្រៀ១ កូនរបស់នាងគឺវាក្វបិត១ កុចំរេង១ កុឱវ៉្ទសិ១, ---(កុ)---(កុ)--- កូនរបស់នាងគឺវាច្កប១ វាយ-នះ១, កូនរបស់នាងគឺវាពោហិណិ១, កុវ៉ោអញឆេទ១, កុអនង១, កុលយេ១ កូនរបស់នាងគឺវាបទិហត១ វាអវៃនុមត១ វាត្បញ១ វាតឥស១ វាតឱង១ វាលាក១ វាត្មេង១។

*__សម្គាល់៖__ នៅក្នុងសេចក្តីបកប្រែនេះ រក្សាពាក្យបុរាណមួយចំនួនដូចជា «កុ» ជាឋានន្តរនាមសម្គាល់អ្នកបម្រើស្រី និង «វា» ជាឋានន្តរនាមសម្គាល់អ្នកបម្រើប្រុស។

## ៤- ពន្យល់ពាក្យ

| | |
|---|---|
| **កន្តៃ/កនិតៃ** | មនុស្សស្រី ពាក្យសម្គាល់មនុស្សស្រី។ |
| **កុ** | ឋានន្តរនាមសម្គាល់អ្នកបម្រើភេទស្រី។ |
| **កោនិ** | កូន។ |
| **ទុក៌** | ទុក រក្សា ស្ថាបនា កសាង ប្រតិស្ឋាន។ |
| **បុយាង្វៃ** | លោក អៃម៉ូនីញ៉េរ ពន្យល់ថាជាពាក្យចាម្ប៍ សម្គាល់មនុស្សស្រី។ |
| **បុយាងអញ** | លោក អៃម៉ូនីញ៉េរ ពន្យល់ថាជាពាក្យចាម្ប៍ សម្គាល់មនុស្សស្រី។ |

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

| | |
|---|---|
| **ភគវតី** | ពាក្យសម្គាល់ទេពស្រី ជាជាយានៃទេពប្រុសណាមួយ។ |
| **ម្រតាញ** | ឋានន្តរនាមរបស់មន្ត្រីព្រះមហាក្សត្របុព្រាហ្មណ៍ថ្នាក់ខ្ពស់នាសម័យមុនអង្គរ។ |
| **វា** | ឋានន្តរនាមសម្គាល់អ្នកបម្រើភេទប្រុស។ |
| **វ្រះកំម្រតាងអញ** | ក្នុងសិលាចារឹកនេះ ពាក្យនេះជាឋានន្តរនាមសម្គាល់ទេព។ |
| **ត្រីគាលត្រាមស្វាមិ** | ព្រះនាមម្យ៉ាងរបស់ព្រះនារាយណ៍។ |
| **សិតិ** | ប្រូចទឹក សិតលោហៈ។ |

## ឯកសារយោង


Aymonier, E. F. (1900). Cambodia, I: The modern kingdom. *Paris: Ernest Leroux. HRAF translation*.

Cœdès, George. (1942). Inscription de Snày Pol. In *Inscription du Cambodge* (Vol. II, pp. 51-53). Paris: Editions de Boccard.

Finot, Louis. (1915) Notes d'épigraphie. In: *Bulletin de l'Ecole française d'Extrême-Orient*. Tome 15. pp. 1-135; doi : https://doi.org/10.3406/befeo.1915.5229

Parmentier Henri. (1935) Complément à L'Art khmèr primitif. In: *Bulletin de l'Ecole française d'Extrême-Orient*. Tome 35, pp. 1-115; doi : https://doi.org/10.3406/befeo.1935.3939

Website: https://cisark.mcfa.gov.kh/core/showsite.php?id=1419


អត្ថបទដោយ៖ ហ៊ិន ឈុនតេង

# បញ្ជីរូបភាព



សិលាចារឹកស្នាយពល K.៦៦៤ ផ្ទាំងក (រូបថត៖ EFEO_ CAM19764-2&3)



សិលាចារឹកស្នាយពល K.៦៦៤ ផ្ទាំងខ (រូបថត៖ EFEO_ CAM19764-1&4)

អត្ថបទដោយៈ ហ៊ិន ឈុនតេង



សំណៅផ្តិតសិលាចារឹកស្នាយពល K.៦៦៤ ផ្ទាំងកខ

អត្ថបទដោយៈ ហ៊ុន ឈុនតេង



ព្រះវិហារវត្តស្នាយពល (រូបថត៖ CISARK)



សំណល់បុរាណវត្ថុនៅក្នុងខ្ទមអ្នកតាវត្តស្នាយពល (រូបថត៖ CISARK)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង